# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ.០៣៦/២៣.....ន.គ.ស .......

ថ្ងៃ សុក្រ ៥កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ វិច្ឆិកា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសក្រុមហ៊ុន ឬវិទ្យាស្ថាន
## ដើម្បីបណ្តុះបណ្តាលស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs)

**និយ័តករគណនេយ្យនិងសវនកម្ម** (ន.គ.ស.) គឺជាស្ថាប័ននិយ័តករគណនេយ្យនិងសវនកម្មតែមួយគត់នៅកម្ពុជាដែលជាសេនាធិការឱ្យអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារលើការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យ និងសវនកម្មប្រកបដោយការជឿទុកចិត្តពីស្ថាប័នសាធារណៈ ស្ថាប័នឯកជន គណនេយ្យករ សវនករ និងសាធារណជន។ ដើម្បីអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន **ន.គ.ស.** បានដាក់ចេញនូវផែនការបណ្តុះបណ្តាលស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនធំ សហគ្រាសធុនតូច និងមធ្យម អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដើម្បីបញ្ជ្រាបការយល់ដឹងលើស្តង់ដាគណនេយ្យឱ្យបានទូលំទូលាយ ទាំងការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មស្របតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានដែលនឹងត្រូវធ្វើឡើងដោយក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលមានជំនាញវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ដែលមានគុណវុឌ្ឍិខ្ពស់លើវិស័យគណនេយ្យ និងសវនកម្ម។

ក្នុងន័យនេះ **ន.គ.ស.** សូមប្រកាសជ្រើសរើសក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលមានគុណវុឌ្ឍិដូចខាងក្រោម÷

### ១. លក្ខខណ្ឌគុណវុឌ្ឍិ

ក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលអាចចូលរួមក្នុងការដេញថ្លៃបាន លុះត្រាតែជាក្រុមហ៊ុនដែល÷

- បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និងនៅអគ្គនាយកដ្ឋានពន្ធដារ ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- បានអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មពេញលេញ
- មានចំណេះដឹងអំពីស្តង់ដាគណនេយ្យ និងសវនកម្មដែលបានដាក់ឱ្យអនុវត្តជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា
- មានបទពិសោធន៍បណ្តុះបណ្តាលក្នុងវិស័យគណនេយ្យ និងសវនកម្មរយៈពេលយ៉ាងតិច៥ឆ្នាំ
- ធ្លាប់បានចូលរួមក្នុងការអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា ត្រូវបានលើកទឹកចិត្ត។

### ២. សមិទ្ធផលដែលត្រូវផ្តល់

ក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលទទួលជោគជ័យក្នុងការដេញថ្លៃ ត្រូវផ្តល់ជូន **ន.គ.ស.** នូវការបណ្តុះបណ្តាលស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs) ជូនដល់សិក្ខាកាម ដែលកំណត់ដោយ **ន.គ.ស.** បានគ្រប់ចំនួន និងទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាពខ្ពស់ដោយភ្ជាប់បង្ហាញជាមួយនូវរបាយការណ៍ការបណ្តុះបណ្តាល។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០២៣ ៨៨២ ១១១
Phone: 023 882 111

**៣. តម្រៃ**

កម្រៃសម្រាប់ការបណ្តុះបណ្តាល គឺបើកចំហរសម្រាប់ការចរចារ។

**៤. រយៈពេលសម្រាប់ការបណ្តុះបណ្តាល**

ការបណ្តុះបណ្តាលស្តង់ដាគណនេយ្យខាងលើនេះមានរយៈពេលមិនលើស២ (ពីរ) ខែ។ ក្នុងករណីមានការបន្ត ឬពន្យារពេលក្នុងបណ្តុះបណ្តាលលើស ២ (ពីរ) ខែ នឹងត្រូវមានការពិភាក្សា និងចរចារ។

កិច្ចសន្យានៃការផ្តល់សេវាបណ្តុះបណ្តាលនឹងត្រូវបង្កើតឡើងរវាង **ន.គ.ស.** ជាមួយនឹងក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលបានទទួលជោគជ័យក្នុងការដេញថ្លៃ។

**៥. ការដាក់ពាក្យ**

ក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលមានចំណាប់អារម្មណ៍ សូមផ្ញើសេចក្តីចំណាប់អារម្មណ៍មក **ន.គ.ស.** តាមរយៈអ៊ីម៉ែល t.satya@acar.gov.kh និង h.sokunthea@acar.gov.kh មក **ន.គ.ស.** ឱ្យបានត្រឹមថ្ងៃទី ២៦ ខែ ៨ ឆ្នាំ២០២៣ ដាក់ទាំងសំណើបច្ចេកទេស (Technical Proposal) និងសំណើហិរញ្ញវត្ថុ (Financial Proposal)។

ចំពោះក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាល ដែលបានជាប់ក្នុងបញ្ជីសម្រាំងនឹងត្រូវបានជូនដំណឹង។

សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមទាក់ទងតាមអាសយដ្ឋាន ឬលេខទូរស័ព្ទ ដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគារ “ក” ជាន់ទី១ ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរស័ព្ទទាក់ទង និងតេឡេក្រាម ÷ ០៦៩ ៧៨៣ ៩៣៦៨ / ០១២ ៧៩៣ ៣៩៨

**និយ័តករគណនេយ្យនិងសវនកម្ម**